ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាល ខេត្ត ក្រុង ស្នងការនគរបាលខេត្តទាំង ២ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

### និស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០

### ប្រកាស

### ប្រកាសលេខ ១៩៤/០០ ពម.ប្រក

### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន
- យោងលិខិតលេខ ៦២ មស.គក ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០០ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការឯកភាពចំពោះសំណើសុំតែងតាំងលោក សំបូរ ទណ្ឌារិទ្ធ ជាអនុប្រធាននាយកដ្ឋាន
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

**សំរេច**

ប្រការ ១ : តែងតាំងលោក សំបូរ វណ្ណារិទ្ធ ជាអនុប្រធាននាយកដ្ឋានបច្ចេកទេសទទួលបន្ទុកស្ថានីយ៍ផ្សាយក្រៅប្រទេស អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងពត៌មាន ។

ប្រការ ២ : អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា និងសាម៉ីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**លី ឡាយស្រេង**

***